

# ដំណាំម្នាស់

**១-ការរៀបចំរងៈ**

យើងត្រូវភ្ជួររដីឲ្យបានស្អាត ទុកចោល ១សប្តាហ៍ បន្ទាប់មកកាយចង្ហូរ ឬភ្ជួររលូតដែល មានបណ្ដោយ ២០ ម៉ែត្រ និងចន្លោះចង្ហូរប្រវែង ១ម៉ែត្រ រួចដាក់ជីអាចម៍គោ តាមចង្ហូរហើយ លប់ដីពីលើ។

**២- ការដាំម្នាស់**

យើងដាំកូនម្នាស់ពីលើចង្ហូរដែលដាក់ជី អាចម៍








កប់គល់ចូលដី១តឹក

គោ ដែលមានចន្លោះពីគុម្ពមួយទៅគុម្ពមួយ ប្រវែងពី ៣ ទៅ ៤តឹក និងចន្លោះរង ប្រវែង ពី៦ ទៅ ៨តឹក។ យើងត្រូវកប់គល់កូនម្នាស់ចូលទៅក្នុងដីប្រមាណ ១តឹក។

**៣- ការសំអាតស្មៅ ពូនគល់ និងការគ្របរងៈ**

ស្មៅចាប់ផ្ដើមដុះក្រោយយើងដាំរួចរយៈ ពេល ១ខែ យើងត្រូវត្រួតពិនិត្យមើល បើឃើញថា មានស្មៅដុះកំពស់កូនម្នាស់ យើងចាំបាច់ ត្រូវធ្វើការជំរះស្មៅចេញ រួចពូនរងនិងយកស្មៅងាប់ ឬដើមកន្ទ្រាំងខែត្រ ឬអង្កាម ដាក់ពីលើរងអោយបានច្រើន ដើម្បីអោយកើតជាជី និង បន្ថយការលូតលាស់របស់ស្មៅ។

**៤- ការដាក់ជីៈ**

- ❋ ការដាក់ជីទ្រាប់បាតៈ យើងដាក់ជីលាមកសត្វ ប្រមាណ៣ការុង ឬ៣០គីឡូក្រាមពីលើចង្ហូររងប្រវែង២០ម៉ែត្ររួចកាប់ជ្រោយ អោយបានសព្វមុនពេលដាំ។
- ❋ ការដាក់ជីបំប៉នៈ យើងប្រើជីអ៊ុយរ៉េ២ដង និង ជី២០-២០-១៥ ១ដងសំរាប់បំប៉នដើមម្នាស់ឲ្យលូតលាស់ល្អ។ ត្រូវសំអាតស្មៅឲ្យបានស្អាតជាមុនសិន និងត្រូវដាក់ជី ក្រោយភ្លៀងធ្លាក់ សំរាប់រដូវវស្សា។ នៅរដូវប្រាំងយើងត្រូវយក ជីអ៊ុយរ៉េចំនួន កន្លះគីឡូ ក្រាម លាយទឹក១ធុង ចំណុះ២០លីត្រ សំរាប់កូនម្នាស់ ១០០ដើម។ ត្រូវចាក់ស្រោច តាមគល់កុំឲ្យទឹកជីចូលក្នុង បណ្ដូលដើមម្នាស់។



- ❋ លើកទី១ៈ ត្រូវដាក់ជីក្នុងរយៈពេល១ ខែ កន្លះ ក្រោយដាំ ប្រើជីអ៊ុយរ៉េ១គ.ក្រ សំរាប់កូនម្នាស់ ២០០ ដើម។
- ❋ លើកទី២ៈ ត្រូវដាក់ជីក្នុងរយៈពេល ២ខែក្រោយ លើកទី១ ប្រើជីអ៊ុយរ៉េ ម្តងទៀត១គ.ក្រ សំរាប់ កូនម្នាស់ ២០០ ដើម។
- ❋ លើកទី៣ៈ ពេលម្នាស់ចាប់ផ្ដើមចេញផ្កា ប្រើ ជី២០-២០-១៥ ១គ.ក្រ សំរាប់កូនម្នាស់២០០ ដើម។
- ❋ **ចំណាំៈ** យើងអាចប្រើជីទឹកនោម គ្រាំជាមួយ